# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៦៤

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបាបិទបញ្ចប់ការស្តាប់សក្ខីកម្ម ពាក់ព័ន្ធនឹងអង្គហេតុនៃការបោសសម្អាតផ្ទៃក្នុង និងបានចាប់ផ្តើមផ្នែកជំនុំជម្រះស្តីពីបទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។[1] នៅថ្ងៃចន្ទ សាក្សីចុងក្រោយបង្អស់លើផ្នែកជំនុំជម្រះស្តីពីអង្គហេតុនៃការបោសសម្អាតផ្ទៃក្នុង មានរហស្សនាម **2-TCW-850** បានផ្តល់សក្ខីកម្មពីការបោសសម្អាតក្នុងភូមិភាគកណ្តាល ក៏ប៉ុន្តែ សក្ខីកម្មដែលសាក្សីនេះបានផ្តល់ មានភាពខុសប្លែកគ្នាយ៉ាងច្រើន ទៅនឹងសេចក្តីថ្លែងការណ៍មុនៗរបស់គាត់។ នៅពេលរសៀលថ្ងៃចន្ទ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលមានរហស្សនាម **2-TCCP-274** បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់គាត់ ដែលធ្លាប់ត្រូវបានរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងឧបទ្ទហេតុដែលគាត់ត្រូវបានរំលោភសេពសន្ថវៈដោយប្រធានកងរបស់គាត់ នៅក្រោយពេលដែលគាត់បានបដិសេធដោយមិនរួមដំណេកជាមួយនឹងស្វាមីរបស់គាត់។ ដើមបណ្តឹងរដ្ឋប្បវេណីទីពីរនាសប្តាហ៍នេះ គឺអ្នកស្រី **ស៊ូ សុធារី** ជាស្ត្រីប្តូរភេទដែលបានរៀបការជាមួយនឹងស្ត្រីម្នាក់នៅក្នុងខែសីហា ឆ្នាំ១៩៧៧ ដោយសារតែការភ័យខ្លាចដល់អាយុជីវិតរបស់

[1] ចំពោះបទចោទប្រកាន់ទាក់ទងនឹងបទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ រួមមាន៖ ការចោទប្រកាន់លើការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ កម្រិតនៃការអនុវត្ត និងតួនាទីរបស់អាជ្ញាធរ សូមមើលឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ស្តីពី " ដីកាដំណោះស្រាយលើសំណុំរឿង០០២ " (ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១០) ឯកសារលេខ D427 វាក្យខណ្ឌ ២១៦ដល់២២០ និង៨៤២ដល់៨៦០។

គាត់។ នៅថ្ងៃព្រហស្បតិ៍ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម **2-TCCP-232** បានផ្តល់សក្ខីកម្មអំពីការរៀបការរបស់គាត់ ដោយបានរៀបរាប់របៀបដែលគាត់ត្រូវបានបដិសេធ មិនអនុញ្ញាតឲ្យរៀបការជាមួយនឹងគូដណ្តឹងរបស់គាត់ ដោយហេតុផលថា គូដណ្តឹងរបស់គាត់មានសមាជិកគ្រួសារម្នាក់ត្រូវបានយកទៅ "កម្ទេច" ដោយរបបនេះ ហើយដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានរៀបចំអាពាហ៍ពិពាហ៍ ជាមួយនឹងអ្នកដែលគាត់ពុំដែលធ្លាប់ស្គាល់ពីមុនមកទាល់តែសោះ។ មានបញ្ហាផ្លូវច្បាប់ជាច្រើន បានលើកឡើងនៅសប្តាហ៍នេះ រួមមាន៖ សំណើសុំការបញ្ជាក់ថាតើបទរំលោភសេពសន្ថវៈស្ថិតនៅក្រោមបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានដាក់បញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង០០២ វគ្គ២ និងការជំទាស់ទៅលើសំណួរច្រំដែល និងមិនគួរចំណាប់អារម្មណ៍។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ប្រ៊ីតនី អូលីណា ឆៅ (Britni Olina Chau), ម៉ាលេនី ហៃដ៍ (Melanie Hyde), ដាញ៉ែល ម៉ាធើស (Daniel Mattes) ខេតលីន កាហ្វហ្វ្រៀ (Caitlin McCaffrie), និន វុទ្ធី, តាយ លីណា, ធំ ស្ថាពរ និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដាសម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University